# តុលាការ ប្រកាសសាលក្រម សំណុំរឿង រវាងអ្នកនិពន្ធ និងម្ចាស់រោងពុម្ព គីមឡុង តែអ្នកនិពន្ធថា អយុត្តិធម៌

Wednesday, 04 June 2014 16:58 ដោយ: ដើមអម្ពិល (DAP) ID-067

**ភ្នំពេញ ៖** អ្នកនិពន្ធរឿង លោកសាស្ត្រាចារ្យ ផ្នែកច្បាប់ លោក ឥន្ទ យឿន បានស្រែក ថា អយុត្តិធម៌ និងមិនអាចទទួល យកបានទេ ចំពោះការប្រកាស សាលក្រម ពីសំណាក់ចៅ ក្រមសាលា ដំបូងរាជធានីភ្នំពេញ នៅរសៀលថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤នេះ ដែលជា សំណុំរឿង រវាងរូបលោក និងម្ចាស់រោងពុម្ពគីមឡុង ។

សាលាដំបូងរាជធានីភ្នំពេញ បានប្រសាល ក្រមផ្តន្ទាទោស ជនជាប់ចោទ ឈ្មោះ ទ្រីន ឡុង ភេទប្រុស អាយុ ៤២ ឆ្នាំ មានមុខរបររកស៊ី និងជាម្ចាស់រោងពុម្ព គីមឡុង ដែលមានទីតាំងផ្ទះលេខ៧៥ ផ្លូវ២៧៨ សង្កាត់អូឡាំពិក ខណ្ឌចំការមន និងជាម្ចាស់បណ្ណាគារ គីមឡុង ដែលមានទីតាំង ស្ថិត នៅក្នុងអាគារ លេខ៨១១ ផ្លូវព្រះមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានី ភ្នំពេញ ដោយពិន័យគាត់ ជាប្រាក់ និងបង្គាប់ឲ្យគាត់ សងប្រាក់សរុប ចំនួន ១២៥០០ដុល្លារ ពីបទ‹‹រំលោភអ្នកនិពន្ធ ក្នុងការផលិត›› ។

ក្រោយពីការ ប្រកាសសាលក្រម របស់អនុប្រធានសាលាដំបូង រាជធានីភ្នំពេញ លោកចៅក្រម កោ វណ្ណី រួចមក អ្នកនិពន្ធ លោក ឥន្ទ យឿន បានចាត់ទុកថា មានភាពអយុត្តិធម៌ សម្រាប់រូបលោក ដែលជាម្ចាស់បណ្តឹង ពីព្រោះជនដែលត្រូវចោទ មិនត្រូវបាន តុលាការ សម្រេចឃុំខ្លួន ដាក់ ពន្ធនាគារ ហើយសំណង ដែលតុលាការ សម្រេចឱ្យជនត្រូវ ចោទសង រូបលោកនោះ គឺវានៅឆ្ងាយពីអ្វី ដែលលោកបានទាមទារ ។

លោកឥន្ទ យឿន បានថ្លែងប្រាប់មជ្ឈ មណ្ឌលព័ត៌មាន ដើមអម្ពិល តាមទូរស័ព្ទនៅ រសៀលថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤នេះ ថា លោករួមជាមួយមេធាវី របស់ខ្លួនបាន នឹងកំពុងពិចារណា ដាក់ពាក្យបណ្តឹង ទៅសាលា ឧទ្ធរណ៍ ដើម្បីប្តឹងជំទាស់ សាលក្រមរបស់ សាលាដំបូង រាជធានីភ្នំពេញ។

សាស្ត្រាចារ្យផ្នែកច្បាប់រូបនេះ បានបញ្ជាក់ថា នៅវេលាម៉ោង២និង៣០នាទី រសៀលថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៤ លោកចៅក្រម កោ វណ្ណី បានប្រកាសសាលក្រមដោយ សម្រេចឱ្យ ជនត្រូវចោទ សងសំណង១ម៉ឺនដុល្លារ ទៅឱ្យភាគីដើមបណ្តឹង ប៉ុន្តែមិនសម្រេច ដាក់ពន្ធនាគារ នោះឡើយ ។ ចំពោះសាលក្រមរបស់ លោកចៅក្រម ខាងលើនេះ ត្រូវបាន លោក ឥន្ទ យឿន អះអាងថា ជារឿងអយុត្តិធម៌ សម្រាប់រូបលោក ហើយ មិនអាចទទួល យកបាននោះឡើយ ពីព្រោះ ជនត្រូវចោទ មិនរៀងចាល នៅពេលដែលតុលាការ មិនសម្រេចឃុំខ្លួន ។

លោកឥន យឿន ដែលជាសមាជិក ប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (ECOSOCC) នៃ ទីស្តីការគណៈរដ្ឋមន្ត្រី ជាសាស្ត្រាច្បាប់ និងជាអ្នកនិពន្ធ (ម្ចាស់សៀវភៅ) និងជាភាគីដើមបណ្តឹង បានបញ្ជាក់ថា ‹‹ចំពោះសាលក្រម តុលាការនេះ លោកមិនទាន់ សម្រេចថា តើនឹងត្រូវបន្តប្តឹងទៅ សាលាឧទ្ធរណ៍ទៀត ឬ យ៉ាងណាពីព្រោះ ត្រូវរង់ចាំពិចារណា ជាមួយមេធាវី ការពារក្តី ក្រុមអ្នកពន្ធ និងមិត្តភក្តិ  របស់គាត់សិន ពីព្រោះនៅក្នុង សាលក្រម តុលាការនេះ តុលាការមិនបាន សម្រេចទោសជាប់ពន្ធនាគារ  នោះទេ ដែលការនេះ អាចនឹងធ្វើ ជនល្មើស នឹងមិនរាងចាល និងបន្តប្រព្រឹត្តរំលោភលើសិទ្ធិអ្នកនិពន្ធ នៅក្នុងប្រទេសកម្ពុជាបន្តទៀត››។

ចំណែកឯការសងជម្ងឺចិត្តទៀតសោត គឺលោកមិនអាចទទួល យកបានទេ ពីព្រោះ វាស្ថិតនៅឆ្ងាយពីអ្វី ដែលលោក អាចទទួលយកបាន និងមិនសមទៅនឹងទំហំ នៃការខូចខាត ដែលលោកមាន ។ សម្រាប់ការប្រកាសសាលក្រមនេះ អ្នក និពន្ធ វ័យ ៤៣ឆ្នាំ លោកឥន្ទ យឿង បាន លើកឡើងនូវ ហេតុផល ៣ធំៗ រួមមានទី១ ធ្វើឱ្យអ្នកនិពន្ធ ដទៃទៀត បាក់ទឹកចិត្ត ទី២ ធ្វើឱ្យជនដែលប្រព្រឹត្ត នូវទង្វើបែបនេះ មិនរៀងចាល និងទី៣ ធ្វើឱ្យយុវជនជំនាន់ក្រោយ ពីមានឯកសារអាន និងរៀនសូត្រ ហើយធ្វើឱ្យក្រុមវិនិយោគ ពីបរទេសលែង ហ៊ានមករកស៊ី នៅស្រុកខ្មែរ ។

លោកកោ វណ្ណី  ប្រធានចៅក្រមជំនុំជម្រះ នៃ សាលាដំបូងរាជធានីភ្នំពេញ បានអានសាលក្រមថា ‹‹តុលាការសម្រេចផ្តន្ទាទោស ជនជាប់ចោទ មានឈ្មោះ ទ្រីន ឡុង ភេទប្រុស អាយុ ៤២ ឆ្នាំ មានមុខរបររកស៊ី និងជាម្ចាស់រោងពុម្ព គីមឡុង និង បណ្ណាគារគីមឡុង  ដោយពិន័យ ជាប្រាក់ចំនួន១០លានរៀល សម្រាប់ដាក់ចូល ក្នុងថវិកាជាតិ និងបង្គាប់ សងជម្ងឺចិត្ត រដ្ឋប្បវេណី ចំនួន១ម៉ឺន ដុល្លារអាមេរិក ទៅភាគីដើមបណ្តឹងឈ្មោះ យឿន ភេទប្រុស អាយុ ៤៣ឆ្នាំ››។

លោកកៅ វណ្ណី បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ ទ្រីន ឡុង ត្រូវបានចោទប្រកាន់ពី តំណាងអយ្យការពីបទ ‹‹រំលោភសិទ្ធិអ្នកនិពន្ធ ក្នុងការផលិត›› តាមបញ្ញត្តិមាត្រា៦៤ នៃ ច្បាប់ស្តីពីសិទ្ធិ អ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ប្រព្រឹត្តនៅទីតាំង បណ្ណាគារ គីម ឡុង ផ្ទះលេខ៨១១ ផ្លូវព្រះមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន និង ទីតាំងផ្ទះលេខ៧៥ ផ្លូវ២៧៨ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃ ទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣។

ទាក់ទងនឹង ករណីខាងលើនេះ លោក ឥន យឿន បានឲ្យដឹងថា រោងពុម្ពគីម ឡុង កន្លងមកបានទទួលបោះ ពុម្ពសៀវភៅ របស់គាត់ ដូចជា សន្ទានុក្រមពាក្យ ច្បាប់ចំនួន ២០០០ក្បាល នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ភាគ១ និងភាគ២ ចំនួន ៦០០០ ក្បាល និង សៀវភៅស្ថាប័នរដ្ឋ បាល នៃ ព្រះរាជាណាចក្រកម្ពុជា ចំនួន២០០០ ក្បាល និង សៀវភៅជាច្រើន មុខទៀត ។

រោងពុម្ពគីមឡុង និងបណ្ណាគារ គីមឡុងថត និងផ្តិតរូប បាន រំលភសិទ្ធិ អ្នកនិពន្ធ ដោយបានលួច យកសៀវភៅ សន្ទានុក្រមពាក្យច្បាប់ បញ្ចេញទៅ លក់ក្នុងបណ្ណាគារ គីមឡុង ថត និងផ្តិតរូប នូវសៀវភៅច្បាប់ដើម ចេញពីរោងពុម្ព ដោយ មិនមានបោះពុម្ព ត្រាសម្គាល់ពីរូបលោក ជាម្ចាស់សៀវភៅ ដែលគាត់បានទៅឃើញលក់ នៅលើទីផ្សារ និងបានទិញដោយផ្ទាល់ ចំនួន៣លើក និងមានរូបថត ជាភស្តុតាង នៅក្នុងខែធ្នូ ឆ្នាំ២០១៣។

បន្ថែមពីលើនេះ កាលពីខែ តុលា ឆ្នាំ ២០១៣ គាត់ បានទៅឃើញ សៀវភៅរបស់គាត់ ជាច្រើនក្បាលទៀត មិនមានបោះត្រាសម្គាល់ និង បានលក់សៀវភៅ ខាងក្រោយវិទ្យាល័យព្រះស៊ីសុវត្ថិ តូបសៀវភៅលេខ៨ ដែលមានម្ចាស់ គឺណា ហើយ គាត់បានទិញចំនួន ២ ក្បាល គឺនីតិគ្រួសារ និង អាពាហ៍ពិពាហ៍ភាគ១ និង ភាគ២ ចំនួន១ក្បាល និង សៀវភៅស្ថាប័ន រដ្ឋបាល នៃ ព្រះរាជាណាចក្រកម្ពុជា ចំនួន១ ក្បាល ដែលគ្មានបោះត្រា សម្គាល់ ដើម្បីទុកជាភស្តុតាង ផងដែរ›› ។

សូមបញ្ជាក់ថា អ្នកនិពន្ធឥន្ទ យឿន បាន ប្តឹងម្ចាស់ រោងពុម្ភគីមឡុង ដោយចោទថា បានលួចយក សៀវភៅ ដែលលោកនិពន្ធទៅ លក់ក្នុងបណ្ណាគាររបស់ខ្លួន ដោយមិនមាន បោះត្រាសម្គាល់ពី រូបលោក ប៉ុន្តែករណីនេះ ត្រូវបានម្ចាស់ រោងពុម្ភគីមឡុង អះអាងថា ជាកំហុសអចេតនា លើការគ្រប់គ្រងមិនដិត ដល់របស់បុគ្គលិក ដែលច្រឡំយកសៀវភៅ ១៥ក្បាលចេញពីរោងពុម្ភ ទៅដាក់លក់នៅ ក្នុងបណ្ណាគារ៕




**អ្នកនិពន្ធ លោក ឥន្ទ យឿន នៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីស្តាប់ការប្រកាស សាលក្រម**